ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

## MINISTRY OF RURAL DEVELOPMENT

**គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា-អាស៊ីអាគ្នេយ៍ជំហាន២**

**Cambodia Southeast Asia Disaster Risk Management 2 Project (KH-SEADRM2)**

# ផែនការស្តីពីការជំរុញ ការចូលរួមរបស់ភាគីពាក់ព័ន្ធ

កំណែចុងក្រោយ

(ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២)

មាតិកា


**ពាក្យអក្សរកាត់ និងសន្ទានុក្រម** ..... V
**ខ្លឹមសារប្រតិបត្តិសង្ខេប** ..... VI
**១. ការពិពណ៌នាគម្រោង** ..... 1
*១.១. ទិដ្ឋភាពទូទៅ* ..... 1
*១.២. ទិសដៅនៃការអភិវឌ្ឍន៍របស់គម្រោង និងសមាសភាគ គម្រោង* ..... 2
*១.៣. គោលបំណងនៃផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ* ..... 3
*១.៤. បទប្បញ្ញត្តិ និងតម្រូវការ* ..... 4
**២. ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងការវិភាគ** ..... 4
*២.១. ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់* ..... 5
*២.២. ភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍* ..... 6
*២.៣. បុគ្គលម្នាក់ៗ និងក្រុម ងាយរងគ្រោះ* ..... 7
*២.៥. សេចក្តីសង្ខេបនៃតម្រូវការអ្នកពាក់ព័ន្ធគម្រោង* ..... 26
**៣. កម្មវិធីការចូលរួមរបស់ភាគីពាក់ព័ន្ធ** ..... 32
*៣.១. គោលបំណង និងការកំណត់ពេលវេលាចូលរួមក្នុងកម្មវិធី របស់អ្នកពាក់ព័ន្ធ* ..... 32
*៣.២.១. អំឡុងពេលរៀបចំគម្រោង* ..... 32
*៣.២.២. អំឡុងពេលអនុវត្តគម្រោង* ..... 33
*៣.៣. យុទ្ធសាស្ត្រ ពិគ្រោះយោបល់* ..... 34
*៣.៤. សង្ខេបសកម្មភាពជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណាក់រៀបចំគម្រោង* ..... 44
*៣.៦. ការកំណត់ពេលវេលា* ..... 50
*៣.៧. ការពិនិត្យឡើងវិញនៃមតិយោបល់* ..... 51
*៣.៩. ដំណាក់កាលបន្ទាប់* ..... 53
**៤. ធនធាន និងទំនួលខុសត្រូវក្នុងពេល អនុវត្តសកម្មភាព ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ** ..... 54
*៤.១. ធនធាន* ..... 54
*៤.២. មុខងារ និងទំនួលខុសត្រូវនៃការគ្រប់គ្រង* ..... 55
**៥. យន្តការដោះស្រាយការសោកស្តាយ** ..... 57
*៥.១. មុខងារ និងទំនួលខុសត្រូវនៃការគ្រប់គ្រង* ..... 57
**៦. យន្តការដោះស្រាយការសោកស្តាយ** ..... 60
*៦.១. គោលបំណងនៃ យន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង (GRM)* ..... 60
*៦.២. សេចក្តីសង្ខេបនៃនីតិកម្មជាតិទាក់ទងនឹងបណ្តឹងសារទុក្ខ និងបណ្តឹងតវ៉ា* ..... 61
*៦.៣. គោលការណ៍នៃ យន្តការដោះស្រាយបណ្តឹងតវ៉ា របស់គម្រោង* ..... 61

*៦.៤. ការពិពណ៌នាអំពីនីតិវិធីដោះស្រាយបណ្តឹងតវ៉ា*.....62
*៦.៤.១. នីតិវិធីដោះស្រាយបណ្តឹងតវ៉ាទាក់ទងនឹងការបរិច្ចាគឬលទ្ធកម្មដីធ្លី*.....63
*៦.៤.២. នីតិវិធីដោះស្រាយបណ្តឹងតវ៉ាទាក់ទងនឹងលក្ខខណ្ឌការងារ និងការងារ*.....65
*៦.៤.៣. នីតិវិធីជួសជុលសម្រាប់ពាក្យបណ្តឹងតវ៉ាទាក់ទងនឹង ការរំលោភបំពាននិងការបៀតបៀនផ្លូវភេទ 67*
*៦.៤.៤. នីតិវិធីដោះស្រាយសម្រាប់បណ្តឹងតវ៉ាទូទៅ*.....69
*៦.៥. ការចុះបញ្ជីបណ្តឹងតវ៉ាគម្រោង*.....69
**៧. ថ្លៃចំណាយ និងថវិកា**.....70
*៧.១. ថ្លៃចំណាយ*.....70
*៧.២. ថវិកា*.....70
**ឧបសម្ព័ន្ធ**.....73
ឧបសម្ព័ន្ធទី១: គំរូរបាយការណ៍ចងក្រងលទ្ធផលកិច្ចពិគ្រោះយោបល់.....73
ឧបសម្ព័ន្ធទី២: វិធីសាស្ត្រសម្រាប់ការចូលរួមចំណែករបស់អ្នកពាក់ព័ន្ធ.....74
ឧបសម្ព័ន្ធទី៣: សេចក្តីណែនាំស្តីពីការបង្កើតសៀវភៅកត់ត្រាបណ្តឹងតវ៉ា.....76
ឧបសម្ព័ន្ធទី៤: សេចក្តីសង្ខេបនៃកិច្ចពិគ្រោះយោបល់.....78

បញ្ជីតារាង

**តារាងទី 1: យុទ្ធសាស្ត្រពិគ្រោះយោបល់សម្រាប់ការលើកកម្ពស់ការចូលរួមពេញលេញរបស់ក្រុមងាយរងគ្រោះ** ...... 8
តារាងទី 2: បញ្ជីម៉ាទ្រីកស្តីពីភាគីឬអ្នកពាក់ព័ន្ធ ...... 11
តារាងទី 3: ការវិភាគអីពីភាគីឬអ្នកពាក់ព័ន្ធ នៅក្នុងសមាសភាគទី២ ...... 19
តារាងទី 4: តម្រូវការការទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ...... 27
តារាងទី 5: ការប្រកាសផ្សព្វផ្សាយឯកសារគម្រោង ...... 35
**តារាងទី 6: វិធីសាស្ត្រពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ** ...... 38
តារាងទី 7:  ការរៀបចំវគ្គពិគ្រោះយោបល់នៅក្នុងអំឡុងពេលរៀបចំគម្រោង ...... 44
តារាងទី 8: តារាងកំណត់ពេលវេលាអនុវត្តន៍សកម្មភាព ...... 50
តារាងទី 9: មន្ត្រីសង្គម និងបរិស្ថាន របស់អង្គភាពគ្រប់គ្រងគម្រោង និងព័ត៌មានសម្រាប់ទំនាក់ទំនង ...... 54
តារាងទី 10 – ការទទួលខុសត្រូវនៅក្នុងការអនុវត្តផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ...... 56
តារាងទី 11: សកម្មភាពសំខាន់ៗ និងថវិកាសម្រាប់គាំទ្រការអនុវត្ត ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (គិតជាដុល្លារអាមេរិក( ...... 70

# ពាក្យអក្សរកាត់ និងសន្ទានុក្រម

| | |
|---|---|
| DDIS | Detailed Design and Supervision (Consultant) |
| ESCP | Environmental and Social Commitment Plan |
| ESF | Environmental and Social Framework |
| ESMF | Environmental and Social Management Framework |
| ESMP | Environmental and Social Management Plan |
| ESO | Environment and Social Office |
| ESS | Environmental and Social Standards |
| FPIC | Free Prior and Informed Consent |
| GDR | General Department of Resettlement |
| IP | Indigenous Peoples |
| IPP | Indigenous Peoples’ Plan |
| IPPF | Indigenous Peoples Planning Framework |
| ISWSC | Implementation Support and Works Supervision Consultant |
| LMP | Land Management Plan |
| MPWT | Ministry of Public Works and Transport |
| MRD | Ministry of Rural Development |
| NGO | Non-Government Organization |
| RGC | Royal Government of Cambodia |
| RP | Resettlement Plan |
| RPF | Resettlement Policy Framework |
| ROW | Right of Way |
| SA | Social Assessment |
| SEP | Stakeholder Engagement Plan |
| SEA | Sexual Exploitation and Abuse |
| SH | Sexual Harassment |
| VAC | Violence Against Children |
| WB | The World Bank |

## ខ្លឹមសារប្រតិបត្តិសង្ខេប

នេះគឺជាឯកសារ ផែនការស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) រៀបចំ ដោយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) សម្រាប់គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SADRM2) ចូលរួមដោយមន្ត្រីទទួលបន្ទុកផ្នែកសង្គមនិងបរិស្ថាន (SEO) របស់ខ្លួន និង គាំទ្រដោយទីប្រឹក្សាជាតិ និងអន្តរជាតិ។ ផែនការស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ នឹងអនុវត្តកម្មវិធីវិនិយោគទាំងឡាយនៅក្រោម គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SADRM 2) ផ្ដល់ហិរញ្ញប្បទានដោយធនាគារពិភពលោក (WB) និងថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា (RGC)។ ផែនការស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ នេះត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌបរិស្ថាន និងសង្គម (ESF) របស់ធនាគារពិភពលោក និងត្រូវបានចាត់ទុកជាឯកសាររស់ អាចកែសម្រួល និងធ្វើបច្ចុប្បន្នភាពស្របតាមការប្រែប្រួលនៃស្ថានភាព ឬវិសាលភាពនៃសកម្មភាព។ ខ្លឹមសារប្រតិបត្តិសង្ខេប មិនបានអធិប្បាយក្បោះក្បាយទេ ដូច្នេះ ផែនការស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងមូលគួរតែត្រូវបានអានដើម្បីយល់ដឹងឲ្យកាន់តែច្បាស់។

## ការពិពណ៌នាសង្ខេបអំពីគម្រោង

គោលបំណងនៃការអនុវត្តគម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SEADRM2) គឺដើម្បីគាំទ្រដល់ការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទដែលត្រូវ រងផលប៉ះពាល់ដោយសារទឹកជំនន់ទឹកភ្លៀងក្នុងឆ្នាំ 2020 និងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការសមាហរណកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទៅក្នុង យុទ្ធសាស្ត្រជាតិស្តីពីភាពធន់ជាមួយគ្រោះមហន្តរាយ សម្រាប់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍។ គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SEADRM 2) នឹងផ្តល់ហិរញ្ញប្បទានដល់ការកសាងឡើងវិញនូវផ្លូវ និងស្ពាននៅតំបន់ជនបទ ប្រមាណពី 200 ទៅ 300 គីឡូម៉ែត្រ ដោយផ្តោត លើខេត្តដែលរងផលប៉ះពាល់ ចំនួន 6 រួមមាន៖ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងសៀមរាប។

## ផែនការស្តីពីជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ

ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) គឺដើម្បីធានាថា សហគមន៍គោលដៅរបស់គម្រោង ក៏ដូចជាភាគីពាក់ព័ន្ធរបស់គម្រោងផ្សេងទៀត ត្រូវបានជូនដំណឹង និងចូលរួមនៅក្នុងគ្រប់ដំណាក់កាលនៃការរៀបចំ និងការអនុវត្តគម្រោង។ គម្រោងទទួលស្គាល់ពីតម្រូវការក្នុងការស្វែងរកតំណាង និងមតិកែលម្អ ដែលរួមបញ្ចូល ហើយ ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នឹងចូលរួមបង្កើតនិងពង្រឹងតួនាទីរបស់ស្ត្រី និងក្រុមងាយរងគ្រោះ ឲ្យកាត់រឹងមាំនៅក្នុងដំណើរការពិគ្រោះយោបល់ នៅថ្នាក់មូលដ្ឋានសហគមន៍។ គម្រោងនេះ ក៏ទទួលស្គាល់ពីសារៈសំខាន់នៃការធានាឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ចូលរួមនៅក្នុងវិធានការកាត់បន្ថយ កម្មវិធីសុវត្ថិភាពផ្លូវថ្នល់ ក៏ដូចជាការបន្តត្រួយតពិនិត្យតាមដានសកម្មភាពគម្រោង។

ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) គូសបញ្ជាក់អំពីភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់៖ អ្នករងផលប៉ះពាល់ដោយផ្ទាល់ពីការជួសជុលផ្លូវថ្នល់ និងអ្នកពាក់ព័ន្ធទាំងឡាយណាដែលចាប់អារម្មណ៍។ ក្រុមចាប់អារម្មណ៍ ឬក្រុមមានកង្វល់ ដោយសារគម្រោង។ ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ពិពណ៌នាអំពីភាគីពាក់ព័ន្ធផ្សេងៗគ្នា ទាំងនេះ ហើយរៀបរាប់អំពីវិធីសាស្ត្រ និងកំណត់ពេលវេលាជាក់លាក់ ដើម្បីឲ្យពួកគាត់បានចូលរួមជាមួយ គម្រោងនៅគ្រប់ដំណាក់ នៃការរៀបចំ និងការអនុវត្តន៍គម្រោង។ ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ក៏ពណ៌នាអំពីប្រភេទព័ត៌មានដែល ត្រូវផ្សព្វផ្សាយនៅពេលអនុវត្តន៍សកម្មភាព ពិគ្រោះយោបល់ និងរបៀបបញ្ចេញមតិយោបល់ ឬទស្សនៈរបស់ភាគីពាក់ព័ន្ធ និងដំណើរការសម្រាប់ដោះស្រាយបណ្តឹងតវ៉ា។

## កម្មវិធីជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ

គោលបំណងសំខាន់នៃកម្មវិធីជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺដើម្បីធានាថា ភាគីពាក់ព័ន្ធរបស់គម្រោងត្រូវបានអនុញ្ញាតឲ្យចូលរួមដោយគម្រោង និងចូលរួមយ៉ាងពេញលេញក្នុងការកិច្ចប្រជុំពិគ្រោះយោបល់ នានា ក្នុងអំឡុងពេលនៃការឌីស្សាញ និងការអនុវត្តគម្រោង ជាពិសេសក្នុងដំណាក់កាល ការផ្តល់ព័ន្ធមានគ្រឡប់របស់ភាគី

ពាក់ព័ន្ធ ដែលលើកឡើង សក្តានុពលហានិភ័យ ដែលធ្វើអាចបង្កផលប៉ះពាល់ដោយសារគម្រោង រួមទាំងវិធានការបន្ធូរបន្ថយផលប៉ះពាល់ ចំណុចនេះគឺ មានសារៈសំខាន់ក្នុងការដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រអន្តរាគមន៍របស់គម្រោង។ គម្រោងនេះនឹងពិគ្រោះយោបល់ជាមួយ ភាគីពាក់ព័ន្ធរបស់គម្រោងផ្សេងៗទៀត នៅដំណាក់កាលខុសគ្នានៃវដ្តគម្រោង ជាពិសេសក្នុងដំណាក់កាលដំបូងនៃការរចនាផ្លូវ និងស្ពាន មុនពេល និងអំឡុងពេលសាងសង់។

## ការពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មាន

ក្នុងអំឡុងពេលរៀបចំគម្រោង ដោយសារការរឹតបន្តឹងលើវិធានការបង្ការ ការរាតត្បាតជំងឺ COVID-19 កិច្ចប្រជុំពិគ្រោះយោបល់ភាគច្រើន ត្រូវបានធ្វើឡើង ដោយប្រើ កម្មវិធី Zoom ។ កិច្ចប្រជុំពិគ្រោះយោបល់សរុបចំនួនប្រាំមួយ (6) ត្រូវបានរៀបចំឡើង ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ 2021 នៅថ្នាក់ជាតិ ខេត្ត និងឃុំសង្កាត់។ គោលបំណងនៃកិច្ចប្រជុំពិគ្រោះយោបល់ គឺដើម្បីពិគ្រោះយោបល់ជាមួយ អ្នកពាក់ព័ន្ធ ដែលងាយនឹងទទួលរងផលប៉ះពាល់ ហើយពួកគាត់មានចំណាប់អារម្មណ៍លើការប្រើឧបករណ៍ ការពារសុវត្ថិភាពបរិស្ថាន និងសង្គម ដែល គម្រោងបានរៀបចំឡើង។ ឧទាហរណ៍ អនុគម្រោងសាងសង់ស្ពាន TK2 ក្នុងខេត្តត្បូងឃ្មុំ មានកិច្ចប្រជុំពិគ្រោះយោបល់ចំនួនបួន ដើម្បីសុំយោបល់ពីប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន អំពីផលប៉ះពាល់ ដែលបង្កដោយគម្រោង និងធ្វើឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានទទួលរងផលប៉ះពាល់។ ណ នៅពេលអនុគម្រោង សាងសង់ផ្លូវ/ស្ពានត្រូវបានអនុម័ត គម្រោងត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងភាគីពាក់ព័ន្ធដែលចាប់អារម្មណ៍ ដោយផ្អែកលើផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងប្រើឧបករណ៍ផ្សេងទៀត ប្រសិនបើ បានរៀបចំសម្រាប់ អនុគម្រោងនិមួយៗ។

ការផ្សព្វផ្សាយសេចក្តីព្រាង ឧបករណ៍ការពារបរិស្ថាព សង្គម រួមទាំង ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ត្រូវបាន បង្ហោះនៅលើគេហទំព័ររបស់ MRD ( https://www.mrd.gov.kh/2021/11/15/4632/ ) នៅថ្ងៃទី 15 ខែវិច្ឆិកា ឆ្នាំ 2021។ សេចក្តីព្រាងនៃឯកសារ នេះត្រូវបានធ្វើបច្ចុប្បន្នភាព ផ្អែកតាមមតិកែលម្អរបស់អ្នកចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងបង្ហាញឡើងវិញនៅក្នុងកំណែឯកសារចុងក្រោយបង្អស់ (នៅលើគេហទំព័រដដែល) នៅថ្ងៃទី XXX ខែធ្នូ ឆ្នាំ 2021 ដើម្បីបន្តធ្វើបច្ចុប្បន្នភាពជាមួយភាគីពាក់ព័ន្ធរបស់គម្រោង។

## ធនធាន និងទំនួលខុសត្រូវ ក្នុងការអនុវត្តសកម្មភាពជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ

អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងទទួលបន្ទុកលើការអនុវត្តសកម្មភាពជំរុញចូលរួមពីភាគីពាក់ព័ន្ធ។ លេខទូរសព្ទសម្រាប់ទំនាក់ទំនង របស់សមាជិកសំខាន់ៗរបស់ PMU ផ្នែកបរិស្ថាន និងសង្គម ដែលអាចទាក់ទងបានដើម្បីផ្តល់មតិយោបល់ កែលម្អ ឬឆ្លើយតបសំណួរអំពីគម្រោង។ ក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិក បញ្ជីឈ្មោះ និងលេខទូសព្ទក៏ត្រូវតែធ្វើបច្ចុប្បន្នភាពដែរ ដើម្បីបង្ហាញប្រព័ន្ធការងារតែមួយ និង ដើម្បីរក្សាការជូនដំណឹងដល់ភាគីពាក់ព័ន្ធរបស់គម្រោង។ ការផ្លាស់ប្តូរក៏នឹងត្រូវធ្វើបច្ចុប្បន្នភាពផងដែរ នៅក្នុងឯកសារផ្សេងទៀតដែលបានផ្សព្វផ្សាយនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាពេលមក និងសម្រប់ប្រើប្រាស់នៅពេលខាងមុខទៀត។

## យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

គោលបំណងនៃ យន្តការដោះស្រាយការសោកស្តាយបណ្តឹងតវ៉ា (GRM) គឺដើម្បីផ្តល់ឱ្យអ្នករងផលប៉ះពាល់ទាំងឡាយនូវនីតិវិធីដោះស្រាយសមស្រប ហើយងាយស្រួលប្រើ សម្រាប់លើកឡើងនូវកង្វល់ ឬសារទុក្ខទាក់ទងនឹងគម្រោង។ យន្តការដោះស្រាយការសោកស្តាយបណ្តឹងតវ៉ា (GRM) នឹងណែនាំអំពីរបៀបដែលពាក្យបណ្តឹងតវ៉ា អាចត្រូវបានកត់ត្រា រួមទាំងទម្រង់ និងប្រព័ន្ធដាក់ពាក្យបណ្តឹងតវ៉ា។ ដើម្បីសម្របសម្រួលដល់ដំណើរការដោះស្រាយបណ្តឹងតវ៉ា ពាក្យបណ្តឹងតវ៉ា ត្រូវរៀបចំជាលាយលក្ខណ៍អក្សរ និងចុះក្នុងបញ្ជី សម្រាប់ដំណើរការដោះស្រាយក្នុងរយៈពេលជាក់លាក់មួយ។ ក្នុងអំឡុងពេលដំណើរការដំណោះស្រាយ ករណីបណ្តឹងតវ៉ា ហើយចាំបាច់ពិភាក្សាជាមួយបុគ្គល ដែលម្ចាស់បណ្តឹងតវ៉ា ដើម្បីឱ្យមានការយោគយល់គ្នា និងធានាដំណើរការដោះស្រាយ ប្រកបដោយប្រសិទ្ធភាព។

## ការត្រួតពិនិត្យ និងការរាយការណ៍

គោលបំណងនៃការត្រួតពិនិត្យតាមដានផ្ទៃក្នុងនៃការអនុវត្តផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) គឺដើម្បីធានាថា សកម្មភាពដែលបានកំណត់ក្នុង ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ត្រូវបានអនុវត្តសមស្រប និងទាន់ពេលវេលា។ ក្រោមការណែនាំរួម របស់នាយក និងអ្នកគ្រប់គ្រងគម្រោង មន្ត្រីទទួលបន្ទុកផ្នែកការការពារបរិស្ថាននិងសង្គម (ESOs) របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាអ្នកទទួលខុសត្រូវចំពោះសកម្មភាពត្រួតពិនិត្យតាមដាន ដូចបានពិពណ៌នានៅក្នុង ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) នេះ។ ក្នុងអំឡុងពេលអនុវត្តគម្រោង មន្ត្រីទទួលបន្ទុកផ្នែកការការពារបរិស្ថាន និងសង្គម (SEOs) នឹងរៀបចំរបាយការណ៍ត្រួតពិនិត្យតាមដានផ្ទៃក្នុងប្រចាំខែ សម្រាប់អនុវត្តន៍សកម្មភាព ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) រួមទាំងសកម្មភាពដែលត្រូវអនុវត្តន៍នៅក្នុងផែនការជនជាតិដើមភាគតិច (IPP)។ ការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (RPs) នឹងត្រូវបានត្រួតពិនិត្យតាមដានដោយ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចបានពិពណ៌នានៅក្នុង គោលនយោបាយស្តីពីក្របខណ្ឌការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (RPF) របស់គម្រោង។

## ថវិកា

ការបង្ហាញខ្ទង់ចំណាយ សម្រាប់អនុវត្តន៍ ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ(SEP) ត្រូវបានប៉ាន់ប្រមាណក្នុងអំឡុងពេលរៀបចំគម្រោង និងការកំណត់គោលបំណងនៃការរៀបចំផែនការថវិកា។ ការចំណាយជាក់ស្តែង នៅក្នុងការអនុវត្ត ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) គឺអាស្រ័យលើវិសាលភាព និងសកម្មភាពដែលត្រូវអនុវត្តន៍ ក្នុងអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ ត្រូវ ធ្វើបច្ចុប្បន្នភាពការចំណាយ នៅពេលដែលបញ្ជីចំណាយរបស់ អនុគម្រោង ត្រូវបានបិទបញ្ចប់។ ការចំណាយសម្រាប់ការចងក្រងឯកសារ ឬផលិតសម្ភារៈឯកសារ និងការផ្សព្វផ្សាយព័ត៌មាន និងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ គប្បី

ត្រូវបានវិភាជន៍ចូលក្នុងខ្ទង់ថវិកាឬមូលនិធិរបស់ក្រសួង/រដ្ឋ  ការប៉ាន់ស្មានថវិកាសម្រាប់ការចំណាយនៅក្នុងការអនុវត្តសកម្មភាព ផែនការស្តីពីការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) របស់គម្រោង ក៏ជាផ្នែកមួយ សំខាន់ដែរ។

# ១. ការពិពណ៌នាគម្រោង

## ១.១. ទិដ្ឋភាពទូទៅ

ចាប់ពីខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ 2020 កម្ពុជាមានភ្លៀងធ្លាក់ខ្លាំងនៅទូទាំងប្រទេស។ ភ្លៀងធ្លាក់ខ្លាំងបានបណ្តាលឱ្យមានទឹកជំនន់យ៉ាងគំហុក ប៉ះពាល់ ខេត្តចំនួន 20 ក្នុងចំណោម 25 ខេត្ត រាជធានី បណ្តាលឱ្យមនុស្សប្រមាណ 800,000 នាក់រងផលប៉ះពាល់ដោយផ្ទាល់ ដែលក្នុងនោះ 49% គឺជាក្រុមងាយរងគ្រោះស្រាប់ពីមុនមក។ ទឹកជំនន់ក៏បានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍សំខាន់ៗ ដែលបណ្តាលឱ្យមានការរំខានដល់ការបណ្តាញផ្លូវដឹកជញ្ជូន ខាតបង់ប្រាក់ចំណូល និង បាត់បង់ទ្រព្យសម្បត្តិ និងអាក់ខានសេវាសាធារណៈសំខាន់ៗមួយចំនួន។ គេបានកត់សម្គាល់ថា គ្រោះទឹកជំនន់ បានកើតឡើងកាន់តែញឹកញាប់និងធ្ងន់ធ្ងរ ខណៈគ្រោះរាំងស្ងួត ក៏បានធ្វើឱ្យប៉ះពាល់កាន់តែធ្ងន់ធ្ងរ ជាពិសេសគ្រួសារងាយរងគ្រោះ ជាច្រើនដែលកំពុងតែជួបការលំបាកស្រាប់តាំងពីមុនមក។ យោងតាមការវាយតម្លៃរហ័សចំពោះការខូចខាត ដោយធនាគារពិភពលោក ការខាតបង់សេដ្ឋកិច្ចដោយសារគ្រោះទឹកជំនន់ បានខាតបង់គិតជាទឹកប្រាក់អស់ប្រមាណ 448-490 លានដុល្លារ។ វិស័យសំខាន់ ដែលរងផលប៉ះពាល់ខ្លាំងជាងគេ គឺវិស័យគមនាគមន៍ ធារាសាស្ត្រ និងកសិកម្ម។ ការចំណាយសរុបសម្រាប់ការស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដែលរងការខូចខាត គិតជាទឹកប្រាក់ អស់ប្រមាណ ៥០៨ លានដុល្លារអាមេរិក។

គោលបំណងរបស់គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ នៅជំហានទី 2 នេះ (KH-SADRM2) គឺដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងឡើងវិញនូវផ្លូវជនបទប្រមាណ 200-300 គីឡូម៉ែត្រ និងស្ពានចំនួន 3កន្លែង នៅក្នុងខេត្តដែលរងផលប៉ះពាល់ហើយត្រូវបានជ្រើសរើសជាខេត្តគោលដៅ (ក្នុងចំណោមខេត្តដែលរងគ្រោះចំនួន 20)។ ខេត្តទាំងនោះរួមមាន ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ និងសៀមរាប។ ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ មិនត្រឹមតែជួយដល់ការស្តារឡើងវិញនូវការតភ្ជាប់បណ្តាញដឹកជញ្ជូនទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំងអាចស្តារជីវភាពរស់នៅរបស់ប្រជាពរដ្ឋ និងថែមទាំងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគមនាគមន៍ដែលមានស្រាប់ និងពង្រឹងភាពធន់ជាមួយគ្រោះទឹកជំនន់ នៅពេលអនាគត និង ផលប៉ះពាល់រយៈពេលវែង នៃការប្រែប្រួលអាកាសធាតុ។ ក្រៅពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគម្រោងនេះ ក៏នឹងពង្រឹងសមត្ថភាពស្ថាប័ននៅក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) សម្រាប់វិស័យអភិវឌ្ឍន៍ជនបទ ជាពិសេសក្នុងដំណើរការរៀបចំផែនការ និងតាក់តែងគោលនយោបាយ។

គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SEADRM 2) ត្រូវបានពិចារណាឲ្យបន្តពី គម្រោង គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 1 (SEADRM1) របស់កម្ពុជាដែលកំពុងដំណើរការ (KH-SEADRM1, P160929)។ គេបានគ្រោងទុកថា សមិទ្ធិផលដែលសម្រេចបានដោយ គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ នៅជំហាន 1 (KH-SEADRM 1) ដូចជាការអភិវឌ្ឍន៍យុទ្ធសាស្ត្រហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ និងសកម្មភាពដែលកំពុងអនុវត្តន៍ក្រោមគម្រោងអភិវឌ្ឍន៍ផ្សេងទៀត រួមបញ្ចូលទាំងការវិភាគគ្រប់ជ្រុងជ្រោយ ក្រោមគម្រោងកែលម្អបណ្តាញភ្ជាប់ផ្លូវ គាំទ្រដោយធនាគារពិភពលោកប្រចាំនៅកម្ពុជា និងគោលការណ៍ណែនាំ ស្តីពីផ្លូវធន់នឹងអាកាសធាតុ ក្រោមគម្រោងកែលម្អផ្លូវជនបទ III របស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់ព័ត៌មានអំពីសកម្មភាពស្នូលរបស់គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅកម្ពុជា អាស៊ីអាគ្នេយ៍ ជំហាន 2 (KH-SEADRM2)។

## ១.២. ទិសដៅនៃការអភិវឌ្ឍន៍របស់គម្រោង និងសមាសភាគ គម្រោង

### ទិសដៅនៃការអភិវឌ្ឍន៍របស់គម្រោង៖

គោលបំណងនៃការអភិវឌ្ឍន៍គម្រោង គឺដើម្បីគាំទ្រដល់ការស្តារឡើងវិញ នូវផ្លូវជនបទ ស្ពាន ដែលធន់នឹងអាកាសធាតុ។ ការស្តារនិងកសាងឡើងវិញនូវផ្លូវជនបទ និងស្ពានដែលរងការខូចខាតដោយទឹកជំនន់នៅក្នុងតំបន់គោលដៅ ការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល ក្នុងការរៀបចំផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្ន។ គោលបំណងនេះ នឹងសម្រេចបានតាមរយៈការអនុវត្តសកម្មភាពផ្សេងៗដែលត្រូវបានរៀបចំ បែងចែកជា បួនផ្នែក ដូចខាងក្រោម៖

- សមាសភាគទី 1៖ ការពង្រឹងស្ថាប័នថ្នាក់ជាតិ សម្រាប់ភាពធន់នឹងគ្រោះមហន្តរាយ (ឥណទាន IDA 0.55 លានដុល្លារអាមេរិក និង 0.45 លានដុល្លារ RETF)។ សមាសភាគនេះ នឹងផ្តោតលើ 21. ការផ្តល់ជំនួយបច្ចេកទេសដើម្បីពង្រឹងសមត្ថភាពមន្ត្រី រាជការ របស់ ក្រសួងកិវឌ្ឍនជនបទ ក្នុងការរៀបចំត្រៀមបម្រុងសម្រាប់ឆ្លើយតប និងការស្តារឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយ និងការដោះស្រាយជាមួយការប្រែប្រួលអាកាសធាតុ។
- ជាតុផ្សំទី 2៖ ការស្តារឡើងវិញដោយភាពធន់ និងការកសាងឡើងវិញនូវផ្លូវ និងស្ពានជនបទ (ឥណទាន IDA 68 លានដុល្លារ)។ ជាតុផ្សំនេះនឹងផ្តោតលើការអនុវត្តការស្តារ និងកសាងឡើងវិញដែលធន់នឹងអាកាសធាតុ និងគ្រោះមហន្តរាយ និងការថែរក្សាផ្លូវ និងស្ពានជនបទដែលបានជ្រើសរើស និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ដែលរងការខូចខាតដោយទឹកជំនន់ឆ្នាំ 2020 និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀតនៅក្នុងតំបន់គោលដៅ។ សមាសភាគនេះក៏ផ្តល់ជំនួយបច្ចេកទេសសម្រាប់៖ (ក) ការការពារអ្នកប្រើប្រាស់ផ្លូវ តាមរយៈការលើកកម្ពស់ការយល់ដឹងរបស់អ្នកប្រើប្រាស់ផ្លូវ។ (ខ) បង្កើតផែនទីបង្ហាញផ្លូវ ដើម្បីពង្រីកមុខងារនៃប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវជនបទ (RRAM) របស់ ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការវាយតម្លៃ និងការស្តារការខូចខាតក្រោយគ្រោះមហន្តរាយ។ និង (គ) ការពង្រឹងសមត្ថភាពក្នុងការងាររចនា (ឌីហ្សាញ) និងការអនុវត្តការស្តារផ្លូវថ្នល់ ស្របតាមស្តង់ដារផ្លូវដែលធន់នឹងអាកាសធាតុ។
- សមាសភាគទី 3៖ ការគ្រប់គ្រងគម្រោង (ឥណទាន IDA 3 លានដុល្លារអាមេរិក ផ្តល់ហិរញ្ញប្បទានសមភាគីចំនួន 1.5 លានដុល្លារ)។ សមាសភាគនេះ នឹងផ្តល់ជំនួយបច្ចេកទេស និងប្រតិបត្តិការ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន អង្គភាព និងបច្ចេកទេសរបស់ ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈការគាំទ្រដល់ការអនុវត្តគម្រោងប្រចាំថ្ងៃ រួមទាំងការសម្របសម្រួល បញ្ហាបច្ចេកទេស កិច្ចការលទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការការពារសង្គម និងបរិស្ថាន ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ។ និងការរៀបចំរបាយការណ៍។
- សមាសភាគទី 4៖ សមាសភាគឆ្លើយតបសង្គ្រោះបន្ទាន់ នៅពេលមានគ្រោះអាសន្ន (CERC) (0 លានដុល្លារអាមេរិក)។ សមាសភាគនេះត្រូវបានរៀបចំឡើងសម្រាប់ឆ្លើយតបភ្លាមៗ និងមានប្រសិទ្ធភាពចំពោះវិបត្តិ ឬគ្រោះអាសន្ននានា ប្រសិនបើ ត្រូវការ។

## ១.៣. គោលបំណងនៃផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ

គោលបំណងនៃផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) គឺដើម្បី ធានាថាភាគីពាក់ព័ន្ធរបស់គម្រោង ជាពិសេសអ្នកទទួលរងផលប៉ះពាល់ ដោយសារគម្រោង ត្រូវបានកំណត់អត្តសញ្ញាណ និងចូលរួមនៅក្នុងដំណើរការរៀបចំ និងអនុវត្តន៍សកម្មភាពគម្រោង។ ក្នុងអំឡុងពេលនៃការអនុវត្ត ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) នេះ គឺភាគីពាក់ព័ន្ធរបស់គម្រោង ជាពិសេសភាគីដែលរងផលប៉ះពាល់ នឹងត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីស្វែងយល់អំពីគោលបំណងរបស់គម្រោង ហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន សំណើវិធានការកាត់បន្ថយផលប៉ះពាល់ យន្តការដោះស្រាយបណ្ដឹងតវ៉ា និងផ្ដល់មតិយោបល់កែលម្អដោយផ្អែកលើ ព័ត៌មានដែលប្រមូលបាន ដើម្បីជួយធ្វើយ៉ាងជៀសវាង ឬកាត់បន្ថយ ហានិភ័យ និងផលប៉ះពាល់ដែលអាចកើតមានក្នុងអំឡុងពេលឌីស្សាញ និងការអនុវត្តគម្រោង។

ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ក៏បានកំណត់ផងដែរ នូវការរៀបចំស្ថាប័នដើម្បីធានាឱ្យ ភាគីពាក់ព័ន្ធរបស់គម្រោងបានការចូលរួមប្រកបដោយប្រសិទ្ធភាព ក្នុងអំឡុងពេលអនុវត្តគម្រោង។ គម្រោងទទួលស្គាល់ថា សំឡេងរបស់ក្រុមជនពិការ ឬក្រុមងាយរងគ្រោះផ្សេងទៀត ដូចជា ស្ត្រីមេគ្រួសារ ជនជាតិដើមភាគតិច ជនពិការ និងធានាថាក្រុមទាំងនេះ មិនទទួលរងផលប៉ះពាល់អវិជ្ជមានបន្ថែមទៀត ក្នុងអំឡុងពេលអនុវត្តគម្រោង។ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) នឹងប្រមូលមតិយោបល់ល្អៗពីអ្នកជួបការលំបាក និងធ្វើការពិចារណា និងដាក់បញ្ចូលទៅក្នុងការរៀបចំ និងការអនុវត្តគម្រោង។ ធានាឱ្យភាគីពាក់ព័ន្ធរបស់គម្រោង ជាពិសេសអ្នកដែលរងផលប៉ះពាល់ មានលទ្ធភាពចូលរួមក្នុងការត្រួតពិនិត្យតាមដានហានិភ័យ និងដំណើរការគ្រប់គ្រងផលប៉ះពាល់របស់គម្រោង តាមរយៈសកម្មភាពត្រួតពិនិត្យតាមដាន និង ផ្ដល់មតិកែលម្អទាន់ពេលវេលា ដើម្បីឱ្យគម្រោង មានលទ្ធភាពគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាព។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)នឹង៖

- កំណត់ភាគីពាក់ព័ន្ធគម្រោង រួមទាំងភាគីដែលរងផលប៉ះពាល់ និងភាគីដែលចាប់អារម្មណ៍។
- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធគម្រោងដើម្បីស្វែងយល់ពីកង្វល់ តម្រូវការអភិវឌ្ឍន៍ អាទិភាពរបស់ពួកគេ ជាពិសេសក្រុមដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងអ្នកដែលជួបការលំបាក ឬងាយរងគ្រោះ។
- ស្វែងយល់ ក្នុងចំណោមភាគីពាក់ព័ន្ធគម្រោង ជាពិសេសក្នុងចំណោមអ្នកមានចំណាប់អារម្មណ៍អំពីសកម្មភាពគម្រោង ថាតើពួកគេមានឥទ្ធិពលយ៉ាងណា និងមានទំហំប៉ុណ្ណាមកលើដំណើរការនៃការរៀបចំ និងការអនុវត្តគម្រោង និងថាតើផលប៉ះពាល់របស់គម្រោងទៅលើពួកគេ មានដូចម្ដេចខ្លះ។
- កំណត់យន្តការដាក់ស្តែង ដើម្បីធានាថា យោបល់កែលម្អរបស់អ្នកពាក់ព័ន្ធ ត្រូវបានដាក់ស្នើ និងឆ្លើយតបសុំទាន់ពេលវេលា (តាមដំណាក់កាលអនុវត្តន៍របស់គម្រោង) និងត្រូវបានពិចារណាដាក់បញ្ចូលទៅក្នុងការដំណើរការរៀបចំ និងការអនុវត្តគម្រោង។

- កំណត់យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានគម្រោង ទៅកាន់ភាគីពាក់ព័ន្ធ ដែលបានកំណត់អត្តសញ្ញាណ ជាពិសេសក្រុមរងផលប៉ះពាល់ជាអវិជ្ជមាន ដើម្បីប្រមូលមតិល្អៗរបស់ពួកគេ សម្រាប់ធ្វើការកែលម្អ។
- កំណត់វិធីសាស្ត្រជាក់លាក់ សម្រាប់ពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធគម្រោង ប្រមូលមតិយោបល់របស់ពួកគេ និងពិចារណាដាក់បញ្ចូល ទៅក្នុងដំណើរការឌីស្សាញគម្រោង។
- ធានាថាយន្តការដោះស្រាយបណ្តឹងតវ៉ា មានរៀបចំនៅតាមទីតាំងអនុគម្រោងនីមួយៗ - សម្រាប់ដោះស្រាយបណ្តឹងតវ៉ា ឬសារទុក្ខ ដែលអាចកើតមានឡើង។ យន្តការដោះស្រាយបណ្តឹងតវ៉ា នឹងត្រូវបានរៀបចំឡើង ដើម្បីដំណើរការដោះស្រាយ ឬឆ្លើយតប និងសមស្របតាមវប្បធម៌ ប្រពៃណីរបស់ប្រជាជននៅក្នុងមូលដ្ឋាន ដែលពួកគេរងផលប៉ះពាល់ ជាពិសេសចំពោះជនជាតិដើមភាគតិច ដែលកំពុងរស់នៅក្នុងតំបន់គោលដៅរបស់គម្រោង។ ធានាបាននូវធនធានមនុស្ស និងធនធានហិរញ្ញវត្ថុសមស្រប សម្រាប់ការអនុវត្ត ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។
- ធានាឱ្យភាគីពាក់ព័ន្ធគម្រោង ទាំងភាគីដែលរងផលប៉ះពាល់ និងភាគីចាប់អារម្មណ៍ មានឱកាសបានចូលរួមត្រួតពិនិត្យតាមដាន ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ក្នុងអំឡុងពេលអនុវត្តន៍គម្រោង។

ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ គឺជាឯកសាររស់ ហើយអាចធ្វើបច្ចុប្បន្នភាពតាមតម្រូវការក្នុងអំឡុងពេលអនុវត្តគម្រោង។

### ១.៤. បទប្បញ្ញត្តិ និងតម្រូវការ

ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នឹងបង្កើតយន្តការអនុវត្តន៍ ដើម្បីធានាឱ្យមានការចូលរួមយ៉ាងពេញលេញ និងប្រកបដោយអត្ថន័យរបស់ភាគីពាក់ព័ន្ធគម្រោង ក្នុងអំឡុងពេលរៀបចំ អនុវត្តន៍ ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង។ យន្តការនេះស្របតាមតម្រូវការនៃអនុក្រឹត្យលេខ 72 អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន (1999) ប្រកាស ស្តីពីគោលការណ៍ណែនាំទូទៅ សម្រាប់រៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ទាំងនៅដំណាក់កាលដំបូង និងពេញលេញ (2009) ស្តង់ដារនីតិវិធីប្រតិបត្តិការ (SOP) ស្តីពីលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ប្រកបដោយដោយស្ម័គ្រចិត្ត (LAR, 2018) និងស្តង់ដារការការពារបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក លេខ 10 ស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការប្រកាសផ្សព្វផ្សាយព័ត៌មានគម្រោង។

## ២. ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងការវិភាគ

នៅក្រោមគម្រោងនេះ ភាគីពាក់ព័ន្ធទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណ រួមមាន៖ ក) ក្រុមមនុស្សដែល រងផលប៉ះពាល់ដោយសារគម្រោង - ទាំងវិជ្ជមាន និងអវិជ្ជមាន (តទៅនេះ គេហៅថា "ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់") និង ខ) បុគ្គលឬក្រុមមនុស្ស ដែលមានចំណាប់អារម្មណ៍អំពីគម្រោង និង/ឬ មានឥទ្ធិពលលើសកម្មភាព ឬសមិទ្ធផលរបស់គម្រោង (តទៅនេះ គេហៅថា "ក្រុមមានចំណាប់អារម្មណ៍)។

## ២.១. ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់

ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ រួមមាន៖ បុគ្គលម្នាក់ៗ សហគមន៍ អាជីវកម្ម ជាដើម ដែលរស់នៅ ឬធ្វើអាជីវកម្មនៅតាមបណ្តោយផ្លូវ ឬក្បែរតំបន់អនុគម្រោងសាងសង់ផ្លូវ និងស្ពាន។ ក្នុងអំឡុងពេលអនុវត្តន៍គម្រោង ប្រជាជនទាំងនោះ អាចរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារ ប្រតិបត្តិការសំណង់ ដូចជា ការកើនឡើងនៃធូលីដី សំឡេង រំញ័រ ការបាត់បង់ទ្រព្យសម្បត្តិគ្រួសារ ដូចជា ដី ផ្ទះ ដំណាំ និងប្រាក់ចំណូល ដោយសារតម្រូវការដី សម្រាប់ការអនុវត្តអនុគម្រោង ឧទាហរណ៍ ការពង្រីកផ្លូវ ឬស្ពាន។ ហានិភ័យអវិជ្ជមាន ដែលអាចកើតមានផ្សេងទៀត រាប់បញ្ចូលទាំង ហានិភ័យទាក់ទងនឹងចរាចរណ៍ និងសុវត្ថិភាពផ្លូវថ្នល់ ការកេងប្រវ័ញ្ចពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន (SEA) ការបៀតបៀនផ្លូវភេទ (SH) អំពើហិង្សាលើកុមារ (VAC) ដោយសារលំហូរនៃកម្លាំងពលកម្ម ដែលត្រូវបានប្រមូលផ្តុំដើម្បីបម្រើការការងារសាងសង់។ ក្នុងដំណាក់កាលប្រតិបត្តិការគម្រោង ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ជាវិជ្ជមាន រួមមាន ប្រជាជនដែលរស់នៅតាមបណ្តោយផ្លូវនៃអនុគម្រោង នឹងអាចជួយធ្វើឲ្យអាជីវកម្មរបស់ពួកគេកាន់តែប្រសើរជាងមុន ដោយសារស្ថានភាពផ្លូវត្រូវបានកែលម្អ និងធ្វើឲ្យមានអតិថិជនចូលកាន់តែច្រើនជាមុន និងផ្លូវថ្នល់ ស្ពាន មានភាពធន់នឹងទឹកជំនន់ ឬអាចប្រើប្រាស់ជាទីទួលសុវត្ថិភាព នៅពេលមានគ្រោះអាសន្នទឹកជំនន់កើតឡើង។

ក្រុមដែលរងផលប៉ះពាល់ជាវិជ្ជមាន (អ្នកទទួលផល)

- អ្នកទទួលផលដោយផ្ទាល់
- អ្នកទទួលផលដោយប្រយោល។

ក្រុមទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបន្ថែម

- បុគគលម្នាក់ៗ/គ្រួសារ ដែលបានបាត់បង់ជម្រក ឬម្លៀសចេញដោយសារ បាត់បង់ផ្ទះសម្បែងទាំងស្រុង និងមិនអាចរកប្រាក់ចំណូលបាន។
  - ប៉ះពាល់លើដីធ្លី និងផ្ទះសម្បែង រួមទាំងការផ្លាស់ប្តូរទីជម្រក ។
  - ប៉ះពាល់ដំណាំ និងដើមឈើ ដែលដុះជាប់នឹងដី - ជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ ហើយដីនោះ ត្រូវបរិច្ចាក ឬប្រគល់ជូនគម្រោងសម្រាប់ការសាងសង់ផ្លូវ ឬស្ពាន។
  - ផលប៉ះពាល់លើសកម្មភាពអាជីវកម្ម (ជាពិសេសអ្នកដែលមានទីតាំងនៅតាមបណ្តោយផ្លូវដែល ត្រូវស្តារឡើងវិញ ឧ. ហាងលក់ទំនិញ ភោជនីយដ្ឋាន សេវាកម្ម។ល។
  - ផលប៉ះពាល់លើគ្រួសារ ជួបការលំបាក ឬងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ខាងលើ (រងផលប៉ះពាល់មិនស្មើភាពគ្នា);
  - ប៉ះពាល់ដោយតម្រូវការ យកដីសាងសង់ ផ្លូវ ឬស្ពាន ប្រសិនបើមាន; និង
  - ប៉ះពាល់ដោយការបរិច្ចាគទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត សម្រាប់ការអនុវត្តគម្រោង។

- ក្រុមហ៊ុនដែលមានសកម្មភាពអាជីវកម្ម ហើយត្រូវបានទទួលរងផលប៉ះពាល់ ដោយសារតែ
  - ការរំខាន និងអតិថិជនមិនអាច ចូលបាន;
  - ការបាត់បង់ខ្លះៗ ឬទាំងស្រុង នូវប្រាក់ចំណូល ដោយសារការបំពុលបរិស្ថាន ក្នុងអំឡុងពេលប្រតិបត្តិការ ការសាងសង់។

- ជនជាតិដើមភាគតិច

  ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី មនុស្សចាស់ និង/ឬជនពិការ កុមារជាដើម អាចជាជនងាយរងគ្រោះ ពាក់ព័ន្ធជាមួយនឹងការចលនាកម្លាំងពលកម្មក្នុងអំឡុងពេលដំណើរការសាងសង់ និង/ឬការធ្វើលទ្ធកម្មដី ដែលស្ថិតនៅចំទីតាំងសម្រាប់អនុវត្តន៍គម្រោង (រាប់ទាំងការប៉ះពាល់បណ្តោះអាសន្ន និង/ឬ ប៉ះពាល់ជាអចិន្ត្រៃយ៍)។ ដោយសារជនជាតិដើមភាគតិច (IP) មានលក្ខណៈពិសេសដោយឡែក ពីសង្គមវប្បធម៌ទូទៅ ហើយអាចងាយទទួលរងផលប៉ះពាល់ នៅពេលពួកគេចូលរួម ជាកម្លាំងពលកម្ម តាមបែបចំណាកស្រុក ហើយ មិនបានត្រូវគេដឹងអំពីបម្រាមប្រពៃណីវប្បធម៌របស់ពួកគេ។ល។

- កម្មករដែលងាយរងគ្រោះ ហានិភ័យ ឬ ផលប៉ះពាល់ផ្សេងៗ ដោយសារតែៈ
  - មិនមានបទប្បញ្ញត្តិ គ្រប់គ្រាន់សម្រាប់ការធានារ៉ាប់រង ប្រឆាំងនឹងការបំផ្លាញ ឬខូចខាត ដល់មនុស្ស ឧបករណ៍ និងទ្រព្យសម្បត្តិ ដែលត្រូវ ដាក់បញ្ចូលក្នុងកិច្ចសន្យា និងកិច្ចសន្យារង ដើម្បីធានាសុវត្ថិភាពការងារ នៅការដ្ឋានសាងសង់។ និង
  - មិនបានវាយតម្លៃអំពីវិធានការទប់ស្កាត់ ដែលត្រូវបានអនុវត្តន៍ជាប្រចាំ ដូចជា ការប្រើកម្លាំងពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ ឬការរំលោភបំពានផ្លូវភេទ (SEA) ការបៀតបៀនផ្លូវភេទ (SH) អំពើហិង្សាលើកុមារ (VAC) អាចកើតមានឡើងនៅអំឡុងពេលប្រើកម្លាំងពលកម្ម សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង។

## ២.២. ភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍

ភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ រួមមាន អ្នកដែលចាប់អារម្មណ៍លើសកម្មភាពគម្រោង និងលទ្ធផល និង/ឬ មាន ឥទ្ធិពលលើការឌីស្សាញ និងដំណើរការអនុវត្តគម្រោង។ ភាគីពាក់ព័ន្ធទាំងនេះ រួមមាន ប្រជាពលរដ្ឋនៅក្នុងសហគមន៍ (ដែលមិនទទួលរងផលប៉ះពាល់ជាអវិជ្ជមានដោយផ្ទាល់ ដោយសារគម្រោង) អាជ្ញាធរពាក់ព័ន្ធ ក្រុមហ៊ុន សហគ្រាស (វិស័យសាធារណៈ និងឯកជន) អង្គការមិនមែនរដ្ឋាភិបាល (NGOs) អ្នកផ្តល់សេវា សេវាសាធារណៈ អ្នកប្រើប្រាស់ផ្លូវ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ទាំងនោះមានដូចជាៈ

- នាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ។ ក្រសួងសាធារណការ និងដឹកជញ្ជូន; ក្រសួងបរិស្ថាន; ក្រសួងសុខាភិបាល; ក្រសួងអប់រំ យុវជន និងកីឡា; អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; ក្រសួងផែនការ; ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់; ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ;
- មន្ទីរជំនាញពាក់ព័ន្ធ នៅថ្នាក់ក្រោមជាតិ រួមមាន មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត (DPWT); សាលាខេត្ត សាលាស្រុក អាជ្ញាធរឃុំ និងភូមិ ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិសាត់ និងសៀមរាប។
- អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) គណៈកម្មាធិការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអន្តរក្រសួង (IRC) អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ថ្នាក់ខេត្ត (PRSC) និងក្រុមការងារ។

- តំណាងគណៈកម្មាធិការស្ត្រី និងកុមារ ថ្នាក់ខេត្ត ស្រុក និងគណៈកម្មការកិច្ចការស្ត្រី ក្រុមសកម្មភាពគ្រប់គ្រងយេនឌ័រ (GMAG) នៅ ក្រសួងអភិវឌ្ឍន៍ជនបទ;
- មន្ទីរជំនាញពាក់ព័ន្ធ នៅថ្នាក់ខេត្ត ដែល ចាប់អារម្មណ៍ ឬចូលរួម ពិគ្រោះយោបល់ លើការស្តារឡើងវិញនូវផ្លូវថ្នល់ រួមទាំង នគរបាលស្រុក តាមបណ្តោយផ្លូវថ្នល់។ មន្ទីរបរិស្ថានខេត្ត; អគ្គិសនីកម្ពុជា; មន្ទីរសុខាភិបាលខេត្ត; មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត; មន្ទីរអប់រំ យុវជន និងកីឡាខេត្ត; មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត; មន្ទីរកិច្ចការនារីខេត្ត; មន្ទីរធម្មការ និងសាសនាខេត្ត; មន្ទីរផែនការខេត្ត; មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត; មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត; មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត;
- អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលដែលមានចំណាប់អារម្មណ៍ លើយេនឌ័រ រួមទាំងបញ្ហាផ្សេងទៀត ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន (SEA) ការបៀតបៀនផ្លូវភេទ (SH) ដូចជា អង្គការបន្ទាយស្រី ជាដើម។
- អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលដែលមានចំណាប់អារម្មណ៍លើបញ្ហាជនជាតិដើមភាគតិច។
- វេទិកាអង្គការមិនមែនរដ្ឋាភិបាល (គណៈនាយកតំណាងអង្គការមិនមែនរដ្ឋាភិបាល);
- អ្នកប្រើប្រាស់ផ្លូវថ្នល់ទូទៅ ដូចជា ប្រជាពលរដ្ឋក្នុងសហគមន៍ ត្រូវទៅផ្សារ សាលារៀន មន្ទីរពេទ្យញឹកញាប់ និងអ្នកដំណើរមិនមែននៅក្នុងសហគមន៍ ត្រូវធ្វើដំណើរឆ្លងកាត់ម្តងម្កាល។
- បណ្តាញសុវត្ថិភាពផ្លូវ;
- អ្នកផ្គត់ផ្គង់សម្ភារៈ សម្រាប់ការសាងសង់ផ្លូវថ្នល់
- អ្នកផ្តល់សេវា ប្រឆាំង អំពើរំលោភបំពាន និងបៀតបៀនផ្លូវភេទ នៅក្នុងស្រុក
- អ្នកសារព័ត៌មានល្បីៗ ដូចជា Fresh News, TVK, BTV; និង
- ប្រជាពលរដ្ឋទូទៅនៅក្នុងសហគមន៍។

## ២.៣. បុគ្គលម្នាក់ៗ និងក្រុម ងាយរងគ្រោះ

បុគ្គលម្នាក់ៗ និងក្រុម ងាយរងគ្រោះ គឺសំដៅទៅលើ ក្រុមមនុស្សដែល ទំនងជាត្រូវទទួលរងផលប៉ះពាល់ ដោយសារ គម្រោង ឬក៏ពួកគេមិនមានឱកាសទទួលបានអត្ថប្រយោជន៍ដូចក្រុមទទួលផលទូទៅ ។ បុគ្គលម្នាក់ៗឬក្រុមងាយរងគ្រោះ គឺជាអនុក្រុម របស់ក្រុមភាគីពាក់ព័ន្ធខាងលើ ដែលបានលើកឡើងនៅក្នុងផ្នែកទី 2.1 (អ្នកពាក់ព័ន្ធដែលរងផលប៉ះពាល់)។ បុគ្គលម្នាក់ៗឬក្រុមមនុស្សទាំងនោះ ក៏ទំនងជាត្រូវបានដកចេញ ឬមិនអាចចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការពិគ្រោះយោបល់ទូទៅ ។ ដូច្នេះ វិធានការ ឬការផ្តល់ជំនួយជាក់លាក់ ដើម្បីអនុញ្ញាតឱ្យពួកគេចូលរួមយ៉ាងពេញលេញ ក្នុងអំឡុងពេលដំណើរការពិគ្រោះយោបល់អំពីគម្រោងគួរតែត្រូវបានអនុវត្តន៍។ គម្រោងនេះនឹងយកចិត្តទុកដាក់អំពីឱកាសខុសៗគ្នារបស់ក្រុមមនុស្សផ្សេងៗគ្នា ក្នុងការចូលរួម នៅក្នុងដំណើរការរៀបចំ និងការអនុវត្តគម្រោង គម្រោង ក៏ដូចជាតម្រូវការទំនាក់ទំនងរវាងគម្រោង និង ក្រុមមនុស្ស និងបុគ្គលម្នាក់ៗ ជាពិសេស ក្រុមជនជាតិដើមភាគតិច ដោយរាប់បញ្ចូលទាំងការគិតគូរអំពីបញ្ហាប្រឈមនានា របស់ពួកគេក្នុងការចូលរួម និងមធ្យោបាយទំនាក់ទំនង លទ្ធភាពនៃការចល័តទី (ធ្វើដំណើរទៅមក)ក្នុងចំណោមមនុស្សចាស់ និងជនពិការ។ ដើម្បីបញ្ចូលគំនិតយោបល់របស់ក្រុមងាយរងគ្រោះទៅក្នុងការដំណើរការរៀបចំគម្រោង ដំបូងត្រូវដោះស្រាយឧបសគ្គនៃការចូលរួមរបស់ពួកគេជាមុនសិន សកម្មភាពយុទ្ធ

សាស្ត្រគប្បីត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ការចូលរួមពេញលេញរបស់ក្រុម ងាយរងគ្រោះ (សូមមើល តារាងទី 1 ខាងក្រោម)។

**តារាងទី 1: យុទ្ធសាស្ត្រពិគ្រោះយោបល់សម្រាប់ការលើកកម្ពស់ការចូលរួមពេញលេញរបស់ក្រុមងាយរងគ្រោះ**

| ល.រ | ក្រុមងាយរងគ្រោះ | វិធីសាស្ត្រពិគ្រោះយោបល់ |
|---|---|---|
| 1 | ក្រុមជនជាតិដើមភាគតិច | • ជម្រុញការចូលរួមរបស់សមាជិកសហគមន៍ជនជាតិដើមភាគត។<br>• ជម្រុញការចូលរួមរបស់ស្ថាប័នតំណាងសហគមន៍ជនជាតិដើមភាគតិច ជនជាតិដើមភាគតិច និងសមាជិកអង្គការឬសមាជិកសហគមន៍ផ្សេងទៀត ដែលសមស្រប។<br>• ការប្រើឧបករណ៍ឃោសនស័ព្ទ ឬសោតទស្សន៍ (មានសម្លេងអាចស្តាប់លឺ និងមានរូបភាពអាចមើលឃើញ) នៅពេលប្រជុំពិគ្រោះយោបល់ជាមួយ ជនជាតិដើមភាគតិច ដោយមានការបកប្រែ ភាសា សម្រាប់ជនជាតិដើមភាគតិច នៅក្នុងតបន់នោះផង។ ប្រើភាសាសរសេររបស់ ជនជាតិដើមភាគតិច ផងដែរ ប្រសិនបើ អាចធ្វើទៅបាន។<br>• ការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ពួកគាត់ ធ្វើការសម្រេចចិត្តជាមួយគ្នាគាត់។<br>• លើកកម្ពស់ការចូលរួមរបស់ពួកគាត់ ប្រកបដោយប្រសិទ្ធភាព ក្នុងអំឡុងពេល ឌីស្សាញគម្រោង ជាពិសេសសម្រាប់អនុគម្រោងនីមួយៗ ដើម្បីធ្វើយ៉ាងណាស្នើសុំមតិយោបល់កែលម្អពីពួកគាត់ ក្នុងការកំណត់វិធានការកាត់បន្ថយ ហានិភ័យ និងផលប៉ះពាល់ ។ |
| 2 | អ្នកដែលមានបញ្ហាផ្នែករាងកាយ | • ការប្រើ សញ្ញាភាសា (ឬប្រើកាយវិការ) និងឧបករណ៍ជំនួយផ្សេងទៀត ប្រសិនបើត្រូវការចាំបាច់។<br>• ការបកប្រែទៅជាភាសាដែលពួកគាត់ងាយយល់ ប្រសិនបើ ពួកគាត់មកពីក្រុម ជនជាតិដើមភាគតិច។<br>• ការផ្តល់មធ្យោបាយធ្វើដំណើរទៅកាន់កន្លែងប្រជុំពិគ្រោះយោបល់។ ប្រសិនបើអាចធ្វើទៅបាន សូមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ នៅក្បែរផ្ទះគាត់ ឬភូមិរបស់ពួកគាត់ ទៅតាមផែនការដែលបានគ្រោងទុក។<br>• ការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ពួកគាត់ ធ្វើការសម្រេចចិត្តដែលមានការឯកភាពជាមួយគ្នាគាត់។<br>• ពេលវេលា និងរយៈពេលប្រជុំ គប្បីសមរម្យសម្រាប់អ្នកចូលរួម |
| 3 | អ្នកមានបញ្ហាផ្លូវចិត្ត | • ពេលវេលាប្រជុំត្រូវតែខ្លី និងមានបរិស្ថានប្រកបដោយផាសុកភាព ងាយស្រួលដល់ការសាកសួរសួរសំណួរ ឬលើកឡើងអំពីបញ្ហាឬកង្វល់ផ្សេងៗ<br>• ការបកប្រែទៅជាភាសាដែលពួកគាត់ងាយយល់<br>• ការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ពួកគាត់ ធ្វើការសម្រេចចិត្ត<br>• រៀបចំកិច្ចប្រជុំដោយឡែកពីគ្នារវាងបុរស និងស្ត្រី |
| 4 | ស្ត្រី | • រៀបចំកិច្ចប្រជុំតូចៗ មានខ្លឹមសារផ្តោតលើស្ត្រី នឹងមានភាពងាយស្រួលដល់ស្ត្រីក្នុងការសួរសំណួរ ឬលើកឡើងអំពីកង្វល់របស់ពួកគាត់។<br>• កំណត់កាលវិភាគប្រជុំ ដែលមិនរំខានដល់សកម្មភាពបំពេញកិច្ចការប្រចាំថ្ងៃរបស់ពួកគាត់។<br>• ទីកន្លែងប្រជុំ គួរតែមានទីតាំងនៅជិតផ្ទះរបស់ពួកគេ។<br>• ប្រើភាសាងាយយល់ សម្រាប់ពួកគាត់។<br>• ការប្រជុំជាមួយ ស្ត្រី គប្បី សម្របសម្រួលដោយអ្នកសម្របសម្រួលជាស្ត្រី។ |

| | | |
|---|---|---|
| 5 | មនុស្សចាស់ | • ការផ្តល់មធ្យោបាយធ្វើដំណើរសម្រាប់ពួកគាត់មកចូលរួម ប្រជុំ។<br>• ពេលវេលា និងរយៈពេល នៃកិច្ចប្រជុំ គប្បីសមស្របទៅតាម ទំហំមតិយោបល់របស់អ្នកចូលរួម ។<br>• ប្រើភាសាងាយយល់ សម្រាប់ពួកគាត់<br>• រៀបចំកិច្ចប្រជុំដាច់ដោយឡែកពីគ្នា រវាងបុរស និងស្ត្រី<br>• សាកសួរ ឬសម្ភាសន៍គាត់ម្នាក់ម្តងៗ។ |
| 6 | កុមារ | • ត្រូវស្នើសុំការយល់ព្រមពីឪពុកម្តាយ/អាណាព្យាបាលរបស់កុមារ<br>• សាកសួរអំពីបញ្ហា សំខាន់ៗរបស់កុមារ ដែលជួបប្រទះប្រចាំថ្ងៃ<br>• ជ្រើសរើសទីកន្លែងដែលសាកសមនឹងកុមារ ឬកន្លែងដែលធ្លាប់ស្គាល់។<br>• ប្រើភាសា ច្បាស់ៗ សមស្របនឹងអាយុរបស់ពួកគេ និងអនុញ្ញាតឲ្យពួកគេនិយាយដោយសេរី។<br>• រៀបចំកិច្ចប្រជុំ ដោយឡែកពីគ្នា រវាងកុមារា និងកុមារី។ |

## ២.៤. ការវិភាគភាគីពាក់ព័ន្ធ

ភាគីឬអ្នកពាក់ព័ន្ធតែងមានកម្រិត ចាប់អារម្មណ៍ខុសៗគ្នា ហើយការចាប់អារណ៍របស់ពួកគាត់អាចមានឥទ្ធិពលលើការឌីស្សាញ និងការអនុវត្តគម្រោង។ ប្រជាជនក្រីក្រ និងប្រជាជនដែលមានជីវភាពធូរធារ ក៏អាចទទួលរងផលប៉ះពាល់ខុសៗគ្នា ទោះបីផលប៉ះពាល់នោះដូចគ្នាក៏ដោយ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹង អំពី៖ ក) កម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធនីមួយៗ ចំពោះការវិនិយោគរបស់គម្រោង។ ខ) ទំហំនៃផលប៉ះពាល់របស់គម្រោងចំពោះពួកគេ ជាពិសេសអ្នកទទួលរងផលប៉ះពាល់ ធ្ងន់ធ្ងរជាងគេ និង គ) រៀបតាមលំដាប់លំដោយនូវកម្រិតនៃផលប៉ះពាល់ ក្នុងចំណោមភាគីឬអ្នកពាក់ព័ន្ធនីមួយៗ ពាក់ព័ន្ធនឹងការឌីស្សាញគម្រោង ដំណើរការអនុវត្តន៍ ក៏ដូចជាលទ្ធផលចុងក្រោយរបស់គម្រោង។ ក្រោមការអនុវត្តគម្រោងនេះ ភាគីឬអ្នកពាក់ព័ន្ធទាំងឡាយ អាចពាក់ព័ន្ធ ខ្លាំងនៅពេលរៀបចំ និងការអនុវត្តគម្រោង រួមមាន ស្ថាប័នរដ្ឋាភិបាល ក្រុមទទួលរងផលប៉ះពាល់ និង អ្នកទទួលផលជាច្រើននៅក្នុងសហគមន៍។ ភាគីឬអ្នកពាក់ព័ន្ធទាំងនោះ ទទួលរងផលប៉ះពាល់ដោយសារគម្រោង ក្នុងពេលតែមួយ ទាំងនៅពេលឌីស្សាញ និងពេលអនុវត្តគម្រោង – ទំហំនៃផលប៉ះពាល់មានវិសាលភាពផ្សេងៗគ្នា។ ចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ ចំពោះការវិនិយោគរបស់គម្រោង ក៏អាចប្រែប្រួលទៅតាមដំណាក់កាលនីមួយៗនៃវដ្តរបស់គម្រោង ដូច្នេះហើយ ការចូលរួមរបស់ពួកគាត់ សំខាន់ណាស់ទាំងនៅដំណាក់កាល ឌីស្សាញគម្រោង និងដំណាក់កាលអនុវត្តន៍គម្រោង។

ដោយផ្អែកលើតួនាទី ទំនួលខុសត្រូវ និងកម្រិតចាប់អារម្មណ៍របស់ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ កិច្ចប្រជុំពិគ្រោះយោបល់ដំបូង ជាមួយពួកគាត់ តារាងទី 1 ខាងក្រោមបង្ហាញអំពីការវាយតម្លៃកម្រិត នៃការចំណាប់អារម្មណ៍ ផលប៉ះពាល់ និងឥទ្ធិពលរបស់ភាគីពាក់ព័ន្ធនីមួយៗ ដែលត្រូវបានកំណត់ក្នុងអំឡុងពេលរៀបចំគម្រោង។ គេក៏បានកត់សម្គាល់ថា កម្រិតនៃការចាប់អារម្មណ៍ ផលប៉ះពាល់ និងឥទ្ធិពលរបស់ពួកគាត់ អាចផ្លាស់ប្តូរក្នុងអំឡុងពេលនៃការរៀបចំ និងអនុវត្តន៍គម្រោង។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នភាពស្វាហាប់នៃចំណាប់អារម្មណ៍ ផលប៉ះពាល់ និងឥទ្ធិពលរបស់ភាគីឬអ្នកពាក់ព័ន្ធ មានពិពណ៌នានៅក្នុងតារាងទី 1 (ម៉ាទ្រីចកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ) គឺប្រយោជន៍ក្នុងការជូនដំណឹង អំពីការរៀបចំយុទ្ធសាស្ត្រការចូលរួមរបស់អ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យ ពីភាគីឬអ្នកពាក់ព័ន្ធគម្រោង។ បញ្ជីឈ្មោះភាគីឬអ្នកពាក់ព័ន្ធត្រូវបានកំណត់ខាងលើ មានពិពណ៌នាបន្ថែមនៅក្នុងតារាងទី 2 (ខាងក្រោម)។ ដោយ

គិតពីចំនួន នៃភាគីឬអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ និងភាគីឬអ្នកពាក់ព័ន្ធដែលទទួលផលប្រយោជន៍ស្រដៀងគ្នា (ដូចជា ក្រសួងពាក់ព័ន្ធជាដើម) ត្រូវបានរៀបតាមក្រុម។

## តារាងទី 2: បញ្ជីម៉ាទ្រីកស្តីពីភាគីឬអ្នកពាក់ព័ន្ធ

| ភាគីដៃគូ | ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ | មុខងារសំខាន់ៗពាក់ព័ន្ធនឹងគម្រោង | ចាប់អារម្មណ៍ កម្រិតណា? | មានផលជះ កម្រិតណា? | មានឥទ្ធិពល កម្រិតណា? |
|---|---|---|---|---|---|
| | | | កម្រិត ខ្ពស់/មធ្យម/ទាប | | |
| ភាគីរងផលប៉ះពាល់ (សហគមន៍) | កម្រិតសហគមន៍ | | | | |
| | អ្នកទទួលរងផលប៉ះពាល់ជាវិជ្ជមាន (អ្នកទទួលផល) | | | | |
| | អ្នកធ្វើដំណើរ និងអ្នកប្រើផ្លូវ (រួមទាំងកសិករ ជនជាតិភាគតិច ស្ត្រី យុវជន កុមារ...) | • ចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង<br>• សំណាកនៃការសំភាសន៍ អ្នកដំណើរ រួមជាមួយនឹងការប្រជុំសាធារណៈ | ខ្ពស់ | មធ្យម | មធ្យម |
| | ពាណិជ្ជការឬអាជីវករ និងអ្នកលក់ដូរតាមដងផ្លូវ | • ចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង<br>• ពិចារណាលើការប្រជុំជាក្រុម ការសំភាសន៍គំរូ | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| | ម្ចាស់ដី និងអចលនទ្រព្យក្នុងស្រុក | • ចូលរួមក្នុងការធ្វើផែនការ និងការអនុវត្តគម្រោង<br>• ការប្រជុំជាមួយបុគ្គលម្នាក់ៗ ដែលជាតំណាងម្ចាស់អចលនទ្រព្យ និង ប្រមូលទិន្នន័យក្នុងអំឡុងពេលស្ទង់មតិ | ខ្ពស់ | មធ្យម | មធ្យម |
| | កម្មករសំណង់ក្នុងស្រុក | • ចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង<br>• ពិចារណាលើការប្រជុំជាក្រុម បន្ថែមពីលើការសម្ភាសន៍ក្នុងអំឡុងពេលប្រមូលទិន្នន័យវិភាគផ្នែកសេដ្ឋកិច្ចសង្គម | ខ្ពស់ | មធ្យម | មធ្យម |
| | ប៉ះពាល់ ធ្ងន់ធ្ងរ | | | | |
| | **ម្ចាស់ដីជនបទមានប័ណ្ណកម្មសិទ្ធិហើយតម្រូវឲ្យបរិច្ចាកសម្រាប់ការអនុវត្តគម្រោង** (រួមទាំងដីកសិកម្ម) | • ចូលរួមក្នុងការពិគ្រោះយោបល់ ផ្តល់មតិកែលម្អលើវិធានការកាត់បន្ថយផលប៉ះពាល់ និងការរៀបចំសំណងផលប៉ះពាល់ | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| | ម្ចាស់អាជីវកម្ម ឬផ្ទះដែលនឹងបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេ | • ចូលរួមក្នុងការពិគ្រោះយោបល់ ផ្តល់មតិកែលម្អលើវិធានការកាត់បន្ថយផលប៉ះពាល់ និងរៀបចំសំណងផលប៉ះពាល់ ឬ/និងការបរិច្ចាគដោយស្ម័គ្រចិត្ត | ខ្ពស់ | ខ្ពស់ | ខ្ពស់ |

| ភាគីដៃគូ | ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ | មុខងារសំខាន់ៗពាក់ព័ន្ធនឹងគម្រោង | ចាប់អារម្មណ៍ កម្រិតណា ? | មានផលជះ កម្រិតណា ? | មានឥទ្ធិពល កម្រិតណា ? |
|---|---|---|---|---|---|
| | | | កម្រិត ខ្ពស់/មធ្យម/ទាប | | |
| | ក្រុមងាយរងគ្រោះ/ជនពិការ រួមមាន ជនជាតិដើមភាគតិច ស្ត្រី មនុស្សចាស់ និងជនពិការដទៃទៀត | • ចូលរួមក្នុងការពិគ្រោះយោបល់ ផ្តល់មតិកែលម្អលើវិធានការកាត់បន្ថយផលប៉ះពាល់ និងរៀបចំសំណងផលប៉ះពាល់ ឬ/និងការបរិច្ចាគដោយស្ម័គ្រចិត្ត។ និង<br>• លើកឡើងអំពីក្តីបារម្ភនានា ទាក់ទងនឹងការធ្វើដំណើរខេញចូលផ្ទះរបស់ពួកគាត់ ក៏ដូចជា ផលប៉ះពាល់ដល់បរិស្ថានជុំវិញក្នុងអំឡុងពេល ប្រតិបត្តិការសាងសង់ផ្លូវទាំងនោះ | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| | ក្រុមហ៊ុន និងអង្គការ | • ចូលរួមក្នុងការពិគ្រោះយោបល់ ផ្តល់មតិកែលម្អលើវិធានការកាត់បន្ថយផលប៉ះពាល់ និងរៀបចំសំណងផលប៉ះពាល់ ឬ/និងការបរិច្ចាគទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| ភាគីចាប់អារម្មណ៍ | **វិស័យសាធារណៈ** | | | | |
| | អាជ្ញាធរថ្នាក់ថ្នាក់ជាតិ | | | | |
| | **ក្រសួងអភិវឌ្ឍន៍ជនបទ** (MRD)<br>• នាយកដ្ឋានផ្លូវជនបទ<br>• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ<br>• នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច<br>• នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង ការឌីស្សាញ ការរៀបចំផែនការ និងការអនុវត្តនៅក្នុងតំបន់ដែលមានផ្លូវជនបទសំខាន់ៗ។ ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច; ការអភិវឌ្ឍន៍សហគមន៍; និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ | ខ្ពស់ | មធ្យម | ខ្ពស់ |
| | ក្រសួងមហាផ្ទៃ (MoI)<br>គណៈកម្មាធិការជាតិនៃលេខាធិការដ្ឋានសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDDS) | • ចូលរួកផ្តល់ មតិយោបល់លើសំណើគម្រោង និងការឌីស្សាញក្នុងឥទ្ធិពលតំបន់ការពារបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ<br>• ចូលរួមផ្តល់នូវមតិយោបល់លើសំណើគម្រោង និងការឌីស្សាញក្នុងឥទ្ធិពលតំបន់ការពារបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ | ខ្ពស់ | ទាប | មធ្យម |
| | គណៈកម្មាធិការ អន្តរក្រសួង (IRC) ស្តីពីការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | • ចូលរួមរៀបចំផែនការគម្រោង និងអនុវត្តនៅក្នុងតំបន់ដែលតម្រូវឲ្យមានការបរិច្ចាគដីធ្លី និង មិនស្ម័គ្រចិត្តទទួលយក សំណងផលប៉ះពាល់ | ខ្ពស់ | ទាប | ខ្ពស់ |

| ភាគីដៃគូ | ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ | មុខងារសំខាន់ៗពាក់ព័ន្ធនឹងគម្រោង | ចាប់អារម្មណ៍ កម្រិតណា? | មានផលជះ កម្រិតណា? | មានឥទ្ធិពល កម្រិតណា? |
|---|---|---|---|---|---|
| | | | កម្រិត ខ្ពស់/មធ្យម/ទាប | | |
| | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF) អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | | | | |
| | ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) នាយកដ្ឋានសុខភាពសាលារៀន | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឪស្សាញក្នុងផ្នែកដែលមានឥទ្ធិពលទាក់ទងនឹងការអប់រំសុខភាព អនាម័យ និងបរិស្ថានសិក្សា អំឡុងពេលអនុវត្តគម្រោង និងវិធានការកាត់បន្ថយផលប៉ះពាល់ | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងបរិស្ថាន (MoE)<br>• អគ្គនាយកដ្ឋានការពារបរិស្ថាន<br>• អគ្គនាយកដ្ឋានរដ្ឋបាល អភិរក្ស និងការពារធម្មជាតិ | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឪស្សាញនៅក្នុងតំបន់ ការពារបរិស្ថាន និងការអភិរក្សធម្មជាតិ។ | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (MCFA)<br>• អគ្គនាយកដ្ឋានបេតិកភណ្ឌ | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឪស្សាញក្នុងតំបន់ អភិរក្សបេតិកភណ្ឌដែលនៅក្បែរនោះ | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងធម្មការ និងសាសនា (MoCR) | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឪស្សាញក្នុងតំបន់ដែលមានវត្ត ព្រះវិហារ និងវិហារឥស្លាម ដែលនៅក្បែរនោះ | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងគ្រប់គ្រងធនធានទឹក និងឧតុនិយម (MoWRAM)<br>• អគ្គនាយកដ្ឋានបច្ចេកទេស | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឪស្សាញនៅក្នុងតំបន់ អភិរក្សធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ សំខាន់ៗ ដែលនៅក្បែរនោះ | មធ្យម | ទាប | ទាប |
| | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)<br>• អគ្គនាយកដ្ឋានការងារ | • ចូលរួមផ្តល់យោបល់លើការរៀបចំផែនការ និងការអនុវត្តគម្រោងដែលមានពាក់ព័ន្ធជាមួយពលកម្មកុមារ និងសុខភាពការងារ | មធ្យម | ទាប | ទាប |

| ភាគីដៃគូ | ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ | មុខងារសំខាន់ៗពាក់ព័ន្ធនឹងគម្រោង | ចាប់អារម្មណ៍កម្រិតណា? | មានផលជះកម្រិតណា? | មានឥទ្ធិពលកម្រិតណា? |
|---|---|---|---|---|---|
| | | | កម្រិត ខ្ពស់/មធ្យម/ទាប | | |
| | ក្រសួងសុខាភិបាល (MoH) | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញនៅក្នុងតំបន់ដែលមានមណ្ឌលផ្តល់សេវាព្យាបាល ថែទាំសុខភាព ឬមន្ទីរពេទ្យ (មណ្ឌលសុខភាពឃុំ) | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញក្នុងតំបន់មានការដាំដុះដំណាំផលិតកម្មបសុសត្វ ព្រៃឈើ និងការអភិរក្សជលផល | ខ្ពស់ | ទាប | មធ្យម |
| | ក្រសួងកិច្ចការនារី (MoWA) | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញ ដែលមានពាក់ព័ន្ធនឹងយេនឌ័រ និងសុខភាពស្ត្រី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ | មធ្យម | ទាប | ទាប |
| | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)<br>• អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម | មធ្យម | ទាប | មធ្យម |
| | ក្រសួងផែនការ (MoP)<br>• អគ្គលេខាធិការដ្ឋាន ប្រជាជន និងការអភិវឌ្ឍន៍ | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញ ដែលមានពាក់ព័ន្ធនឹងប្រជាសាស្ត្រ និងការអភិវឌ្ឍន៍ | មធ្យម | ទាប | ទាប |
| | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)<br>• អគ្គនាយកដ្ឋានបច្ចេកទេស | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឱស្សាញដែលមានពាក់ព័ន្ធនឹងសុខុមាលភាពសង្គម | មធ្យម | ទាប | ទាប |
| | ក្រសួងទេសចរណ៍ | • ចូលរួមផ្តល់មតិយោបល់លើសំណើគម្រោង និងការឱស្សាញដែលមានពាក់ព័ន្ធជាមួយការគ្រប់គ្រង និងថែទាំរមណីយដ្ឋានធម្មជាតិ រមណីយដ្ឋានដែលបង្កើតថ្មី មជ្ឈមណ្ឌលទេសចរណ៍ និងតំបន់អភិវឌ្ឍន៍ទេសចរណ៍ទូទាំងប្រទេស។ | ខ្ពស់ | ទាប | មធ្យម |

| ភាគីដៃគូ | ភាគីឬអ្នកពាក់ព័ន្ធសំខាន់ៗ | មុខងារសំខាន់ៗពាក់ព័ន្ធនឹងគម្រោង | ចាប់អារម្មណ៍ កម្រិតណា? | មានផលជះ កម្រិតណា? | មានឥទ្ធិពល កម្រិតណា? |
|---|---|---|---|---|---|
| | | | កម្រិត ខ្ពស់/មធ្យម/ទាប | | |
| | អគ្គិសនីកម្ពុជា (EDC) | • ចូលរួមផ្តល់យោបល់លើសំណើគម្រោង និងការឌីស្សាញដែលមានពាក់ព័ន្ធជាមួយបណ្តាញអគ្គិសនី | ទាប | ទាប | ទាប |
| | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) | • ចូលរួមផ្តល់មតិយោបល់លើសំណើគម្រោង និងការឌីស្សាញដែលមានពាក់ព័ន្ធជាមួយខ្សែកាបអុបទិក និងប្រៃសណីយ៍ | ខ្ពស់ | ទាប | ទាប |
| | អាជ្ញាធរមូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក ឃុំ) | | | | |
| | អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់នៅថ្នាក់ខេត្ត (ប.ស.ស) និងក្រុមការងារ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ និង សៀមរាប | • ចូលរួមផ្តល់យោបល់លើការរៀបចំផែនការគម្រោង និងការអនុវត្តនៅក្នុងតំបន់ដែលតម្រូវឲ្យមានការបរិច្ចាគដី និង មិនស្ម័គ្រចិត្តទទួលយកសំណងផលប៉ះពាល់ | ខ្ពស់ | ទាប | ខ្ពស់ |
